ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ទីក្រុងស្អាត ត្រូវផ្តើមចេញពីយើងទាំងអស់គ្នា

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

លេខ: ០០៤.គជវ.ទក

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែ ពិសាខ ឆ្នាំ ច ត្រីស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៨

**គោរពជូន**

**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងជា**

**សមាជិកគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**

**កម្មវត្ថុ៖** ការប្រើប្រាស់អក្សរខ្មែរ និងអក្សរបរទេសនៅលើស្លាកយីហោអាជីវកម្មទេសចរណ៍។

**យោង៖** - ច្បាប់ស្តីពីទេសចរណ៍។

- ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល** ជ្រាបថា ដើម្បីចូលរួមចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" និងដើម្បីលើកកម្ពស់សោភ័ណភាពទីក្រុងស្អាត ផ្សារភ្ជាប់ជាមួយនឹងអត្តសញ្ញាណវប្បធម៌ជាតិ ស្លាកយីហោអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម៖

១. អក្សរខ្មែរត្រូវបានសរសេរឱ្យបានធំជាងអក្សរអង់គ្លេស ហើយដាក់នៅជួរខាងលើ

២. អក្សរអង់គ្លេសអាចសរសេរនៅខាងក្រោម និងមានទំហំពាក់កណ្តាលនៃអក្សរខ្មែរ

៣. មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ អាចសរសេរភាសាបរទេសទី៣ នៅបន្ទាប់ទៀត អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃអតិថិជនរបស់អាជីវកម្ម។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវអភិបាល** ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  "ដើម្បីជ្រាប"
- គ្រប់មន្ទីរទេសចរណ៍រាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ